សលាកប័ត្រព័ត៌មាន ៖ កម្រងករណីសិក្សា ៖ ប្រាសាទព្រះវិហារ

រូបភាពរួម ៖ ប្រាសាទព្រះវិហារ និងតំបន់ជុំវិញប្រាសាទស្ថាយជាប្រធានបទនៃជម្លោះរវាងប្រទេសកម្ពុជា និងប្រទេសថៃ ដែលភាគីទាំងពីរប្រជែងគ្នាយ៉ាងក្តៅគគុកលើបូរណភាពដែនដីនេះ។ ការដាក់ប្រាសាទនេះចូលជាបេតិកភណ្ឌអន្តរជាតិក្នុងឆ្នាំ ២០០៨ ធ្វើឲ្យភាពតានតឹងកាន់តែធ្ងន់ធ្ងរឡើង ដែលបណ្តាលឲ្យមានការផ្ទុះអំពើហិង្សាជាបន្តបន្ទាប់ចាប់តាំងពីខែតុលា ឆ្នាំ២០០៨។ សេចក្តីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិនាពេលថ្មីៗ ដែលកំណត់វិធានការណ៍បណ្តោះអាសន្ន ធ្វើឲ្យមានការបង្កើតតំបន់គ្មានយោធាជុំវិញប្រាសាទព្រះវិហារ ប៉ុន្តែការដោះស្រាយជម្លោះជាអចិន្ត្រៃយ៍នៅតែជាការចាំបាច់។

សេចក្តីផ្តើម

ប្រាសាទព្រះវិហារ គឺជាប្រាសាទខ្មែរបែបហិណ្ឌូ ដែលបានត្រូវបានកសាងឡើងដើម្បីឧទ្ទិសដល់អាទិ-ទេពនៃសាសនាហិណ្ឌូគឺព្រះសិវៈ ស្ថិតលើខ្នងភ្នំដងរែកដែលមានកម្ពស់ ៥២៥ម៉ែត្រ ក្នុងភូមិស្វាជ្រុំ ឃុំកណ្តាត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ នៃព្រះរាជាណាចក្រកម្ពុជា (កម្ពុជា) ដែលមានព្រំដែនជាប់ប្រទេសថៃ។ សលាកប័ត្រព័ត៌មាននេះ ពិនិត្យមើលលើប្រវត្តិសាស្ត្រនៃជម្លោះរវាងកម្ពុជា និងថៃដោយសារតែប្រាសាទព្រះវិហារ និងតំបន់ជុំវិញ មើលលើសាលក្រមរបស់តុលាការយុត្តិធម៌អន្តរជាតិឆ្នាំ ១៩៦២ និងការបកស្រាយរបស់តុលាការនេះកាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ និងផលប៉ះពាល់នៃការបោះឆ្នោតក្នុងប្រទេសថៃកាលពីពេលថ្មីៗមក លើជម្លោះព្រំដែនដែលកំពុងតែក្តៅគគុក។ សលាកប័ត្រព័ត៌មាននេះត្រូវបានតាក់តែងឡើងដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ដែលជាអង្គការមិនមែនរដ្ឋាភិបាល មិនចូលបក្សសម្ព័ន្ធ និងឯករាជ្យ ដែលធ្វើការលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

តុលាការយុត្តិធម៌អន្តរជាតិ ៖ សាលក្រមឆ្នាំ ១៩៦២

ជម្លោះលើតំបន់នេះមានឫសគល់មកពីកិច្ចព្រមព្រៀងកំណត់ព្រំដែនជាបន្តបន្ទាប់ដែលបញ្ចប់ក្នុងអំឡុងឆ្នាំ១៩០៤ ដល់ ឆ្នាំ១៩០៨ រវាងប្រទេសបារាំង និងថៃ។ ពេលដែលកម្ពុជាទទួលបានឯករាជ្យពីអាណា-និគមបារាំងក្នុងឆ្នាំ១៩៥៤ ថៃបានកាន់កាប់ប្រាសាទព្រះវិហារ។ ថ្ងៃទី០៦ ខែតុលា ឆ្នាំ ១៩៥៩ ប្រទេសកម្ពុជាដែលទើបទទួលបានឯករាជ្យថ្មីៗ បានរៀបចំនីតិវិធីច្បាប់នៅឯតុលាការយុត្តិធម៌អន្តរជាតិដើម្បីទាមទារការកាន់កាប់ប្រាសាទព្រះវិហារវិញ។ តុលាការយុត្តិធម៌អន្តរជាតិបានកាត់ក្តីជាប្រយោជន៍ដល់កម្ពុជា ប្រកាសសាលក្រមរបស់ខ្លួនថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ១៩៦២។ តុលាការយុត្តិធម៌អន្តរជាតិ បានបញ្ជាក់ថាប្រទេសថៃមានកាតព្វកិច្ចត្រូវដកយោធា កងកម្លាំងប៉ូលីស និងសន្តិសុខ ឬកងរក្សាការពារនានា ដែលឈរជើងក្នុងតំបន់ប្រាសាទព្រះវិហារ ឬដែនដីជុំវិញប្រទេសកម្ពុជា។ ប្រទេសថៃបានប្រកែកនឹងសាលក្រមឆ្នាំ១៩៧២ របស់តុលាការយុត្តិធម៌អន្តរជាតិ និងរក្សាសិទ្ធិក្នុងការស្នើសុំការផ្លាស់ប្តូរសេចក្តីសម្រេច ដូចដែលមានចែងក្នុងមាត្រា៦១ នៃលក្ខន្តិក:របស់តុលាការ ថាអាចស្នើសុំបានក្នុងរយៈពេល ១០ឆ្នាំ ក៏ប៉ុន្តែ អាចជាការភ្ញាក់ផ្អើលមួយផងដែរ ដែលប្រទេសថៃមិនបានដាក់ពាក្យស្នើសុំការផ្លាស់ប្តូរជាផ្លូវការនៅក្នុងរយៈពេលដែលបានកំណត់នោះទេ។

ប្រាសាទព្រះវិហារស្ថាយជាបេតិកភណ្ឌពិភពលោក

ក្នុងឆ្នាំ២០០៧ ប្រទេសកម្ពុជាបានប្រកាសពីចេតនារបស់ខ្លួនដើម្បីចុះបញ្ជីប្រាសាទព្រះវិហារជាបេតិក-ភណ្ឌអន្តរជាតិ ដោយអង្គការការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ (យូណេស្កូ)។

ប្រទេសថៃមិនបានប្រឆាំងនឹងការចុះបញ្ជីនោះទេ តែបានសង្កត់ធ្ងន់ថាការចុះបញ្ជីនេះមិនត្រូវប៉ះពាល់ដល់ខ្សែបន្ទាត់ព្រំដែនដែលកំពុងមានជម្លោះនោះទេ។ ទាំងកម្ពុជា និងថៃ សុទ្ធតែយល់ព្រមស្របគ្នាថា ប្រាសាទព្រះវិហារមាន "តម្លៃជាសកលដែលមិនអាចកាត់ថ្លៃបាន" និងគួរតែចុះនៅក្នុងបញ្ជីរបស់បេតិកភណ្ឌពិភពលោក។ ប៉ុន្តែ គណបក្សប្រឆាំងរបស់ថៃបានវាយប្រហារចំពោះការគាំទ្រនៃការចុះបញ្ជីនេះ ដែលបណ្តាលឲ្យរដ្ឋាភិបាលថៃដកចេញការគាំទ្ររបស់ខ្លួនជាផ្លូវការ។ កម្ពុជានៅតែបន្តការចុះបញ្ជីនេះដោយឯកត្តោភាគី ដោយមិនចាប់អារម្មណ៍នឹងការបដិសេធរបស់ថៃ។ នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៨ គណៈកម្មាធិការបេតិកភណ្ឌពិភពលោករបស់យូណេស្កូ បានចុះបញ្ជីប្រាសាទព្រះវិហារចូលទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ទោះបីជាមានការប្រឆាំងជាផ្លូវការពីប្រទេសថៃក៏ដោយ។ យូណេស្កូ បញ្ជាក់ថា *"ទីតាំងនេះគួរតែត្រូវបានរក្សាជាពិសេសដោយសារជាទីតាំងដាច់ស្រយាល។ ប្រាសាទនេះមានលក្ខណៈពិសេសជាងប្រាសាទដទៃដោយសារតែសំណង់ស្ថាបត្យកម្មដ៏ល្អប្រណិត ដែលរួមផ្សំទាំងមជ្ឈដ្ឋានធម្មជាតិ និងតួនាទីបែបសាសនារបស់ប្រាសាទ និងក៏មានលក្ខណៈពិសេសដោយសារតែថ្មចម្លាក់ដែលត្រូវបានរចនាឡើងយ៉ាងល្អវិសេស"*។

ជម្លោះរាលដាលជាអំពើហិង្សា

ចាប់ពីខែតុលា ឆ្នាំ ២០០៨ ជម្លោះព្រំដែនរវាងកម្ពុជា និងថៃកាន់តែរីករាលដាល ដែលកិច្ចព្រមព្រៀងបញ្ចប់សង្គ្រាមមានប្រសិទ្ធភាពត្រឹមតែមួយភ្លែត ហើយក៏មានការប្រយុទ្ធគ្នាបន្ទាប់ទៀតកើតមានឡើង។ ក្នុងខែមេសា ឆ្នាំ២០០៩ ប្រាសាទព្រះវិហារ ទទួលរងការខូចខាត និងមានការរាយការណ៍ពីការស្លាប់ក្នុងអំឡុងការវាយប្រហាររវាងកងកម្លាំងទាំងពីរ។ មានការបាញ់ប្រហារគ្នាកើតឡើងជាបន្តបន្ទាប់នៅក្នុង និងនៅជុំវិញប្រាសាទព្រះវិហារក្នុងខែកុម្ភៈ ឆ្នាំ២០១១ ដែលថៃបានសារភាពថាបានប្រើគ្រាប់បែកចង្កោម ដែលបណ្តាលឲ្យមានរបួស និងការជម្លៀសប្រជាពលរដ្ឋមួយចំនួនធំក្នុងប្រទេសទាំងពីរ ហើយក៏បានធ្វើឲ្យមានការខូចខាតដល់ប្រាសាទផងដែរ។ ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ភាពប្រទូស្តរ៉ាយបានបន្តក្នុងតំបន់ជុំវិញប្រាសាទតាមាន់ និងតាក្របី ស្ថិតនៅប្រមាណ ១៥០គីឡូម៉ែត្រខាងលិចប្រាសាទព្រះវិហារ (ប្រាសាទទាំងពីរមានចម្ងាយពីគ្នាប្រហែល ១៥គីឡូម៉ែត្រ) និងមានរយៈពេលប្រហែលពីរ ទៅបីថ្ងៃ។ ចាប់តាំងពីឆ្នាំ២០០៨ ជម្លោះដែលមានការរាយការណ៍ថាបណ្តាលឲ្យមានទាហានចំនួន ២៩នាក់ស្លាប់ និងប្រជាពលរដ្ឋប្រមាណជា ៨៥,០០០នាក់ របស់ប្រទេសទាំងពីរ ត្រូវបានជម្លៀសចេញពីព្រំដែន។ ប៉ុន្តែ ដោយសារតែគ្មានវត្តមានរបស់អ្នកសង្កេតការណ៍ឯករាជ្យ ធ្វើឲ្យមានការពិបាកក្នុងការកំណត់ការពិតដែលនៅពីក្រោយ និងការចោទប្រកាន់របស់ភាគីទាំងសងខាង។ កិច្ចព្រមព្រៀងបញ្ចប់ការបាញ់ប្រហារត្រូវបានបន្តរហូតដល់ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១១ ។

តុលាការយុត្តិធម៌អន្តរជាតិ ៖ "ជំហានពីរ"

នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១១ កម្ពុជាបានដាក់ពាក្យស្នើសុំទៅកាន់តុលាការយុត្តិធម៌អន្តរជាតិជាបន្ទាន់ សុំឲ្យមានការបកស្រាយសាលក្រមឆ្នាំ១៩៦២ និងកំណត់នូវវិធានការណ៍បណ្តោះអាសន្ន ក្នុងគោលបំណងដោះស្រាយជម្លោះនេះ និងអភិរក្សប្រាសាទព្រះវិហារបន្ទាប់ពីមានការប្រយុទ្ធក្នុងពេលថ្មីៗ។ បន្ទាប់ពីមានសវនាការលើសំណើរទាំងមកពីកម្ពុជា និងថៃ តុលាការយុត្តិធម៌អន្តរជាតិបានកំណត់វិធានការណ៍បណ្តោះអាសន្ន ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ថា ៖ ប្រទេសទាំងពីរ ត្រូវបានបញ្ជាឲ្យដកកងកម្លាំងយោធាជាអចិន្ត្រៃយ៍ចេញពីតំបន់គ្មានយោធាបណ្តោះអាសន្ន និងដើម្បីអនុញ្ញាតឲ្យមានភាគីសង្កេតអព្យាក្រឹត្យដែលជាប្រទេសទីបី (ឥណ្ឌូនេស៊ី) អាចមានលទ្ធភាពចូលទៅសង្កេតការណ៍ក្នុងតំបន់គ្មានយោធានេះបាន ហើយប្រទេសថៃត្រូវតែគោរពការធ្វើដំណើរដោយសេរីរបស់ប្រទេសកម្ពុជាទៅកាន់ប្រាសាទព្រះវិហារ ក្នុងនោះ នៅមិនទាន់មានការបកស្រាយសាលក្រមឆ្នាំ១៩៦២ របស់តុលាការយុត្តិធម៌អន្តរជាតិនៅឡើយទេ។

ទំនាក់ទំនងរវាងការបោះឆ្នោតក្នុងប្រទេសថៃបច្ចុប្បន្ន និងជម្លោះ

ថ្ងៃទី០៣ ខែ កក្កដា ឆ្នាំ២០១១ គណបក្សប្រឆាំងរបស់ថៃ គណបក្សដើម្បីថៃ បានឈ្នះការបោះឆ្នោតជាមួយនឹងសន្លឹកឆ្នោតដ៏ច្រើនលើសលប់ ដែលមានលោកស្រី យីងឡាក់ សុិនណាវ៉ាត្រា បានស្បថចូលកាន់តំណែងក្នុងថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១។ លោកស្រីសុិនណាវ៉ាត្រា ដែលជាប្អូនស្រីពៅ របស់អតីតនាយករដ្ឋមន្ត្រីលោក ថាក់ស៊ីន សុិនណាវ៉ាត្រា ដែលក្នុងឆ្នាំ២០០៩ និង២០១០ បម្រើការជាទីប្រឹក្សាផ្នែកសេដ្ឋកិច្ចពិសេសដល់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។ ខណៈពេលដែលនាយករដ្ឋមន្ត្រីដែលទើបចុះចេញពីតំណែងនិយាយថាលោកនឹងមិនគោរពតាមសេចក្តីបង្គាប់របស់តុលាការយុត្តិធម៌អន្តរជាតិក្នុងការដកទ័ពចេញទេ ដរាបណាមិនទាន់មានការចរចាគ្នារវាងភាគីទាំងពីរនោះ អ្នកវិភាគជឿថាការបោះឆ្នោតជ្រើសរើសរដ្ឋាភិបាលគាំទ្រលោក ថាក់ស៊ីននៅទីក្រុងបាងកក នឹងធ្វើឲ្យទំនាក់ទំនងរវាងប្រទេសកម្ពុជា និងថៃបានកាន់តែល្អប្រសើរឡើង និងកាត់បន្ថយភាពប្រទូស្តរ៉ាយដែលធ្វើឲ្យទំនាក់ទំនងនោះមានភាពល្អក់កករតាំងពីឆ្នាំ ២០០៨។ រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា លោក ហោ ណាំហុង មានប្រសាសន៍ថា ជ័យជំនះដ៏លើសលប់របស់គណបក្សដើម្បីថៃ ៖ *"ការពិត យើងមិនអាចលាក់កំបាំងបានទេថាយើងពិតជាសប្បាយរីករាយចំពោះជ័យជំនះរបស់គណបក្សដើម្បីថៃនៅទីក្រុងបាងកកនេះណាស់"* ខណៈពេលដែលលោក ហ៊ុន សែនបានបញ្ជាក់ថារដ្ឋាភិបាលដើម្បីថៃនឹងបង្កើតឲ្យមាន *"សម័យកាលថ្មីមួយនៃកិច្ចសហប្រតិបត្តិការ"*។

សេចក្តីសន្និដ្ឋាន

មានការបង្ហាញថាសម័យកាលថ្មីពិតជាចាប់ផ្តើមមែន ដោយសារតែមេបញ្ជាការយោធារបស់ប្រទេសកម្ពុជា និងថៃបានចូលរួមការចរចាកាលពី ថ្ងៃទី២៤-២៥ ខែសីហា ក្រោម "គណៈកម្មាធិការព្រំដែនថ្នាក់តំបន់" ថ្មីមួយ ដើម្បីពិភាក្សាពីការដកកងទ័ពចេញពីតំបន់ជុំវិញប្រាសាទព្រះវិហារ។ ម្យ៉ាងវិញទៀត កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ កងពលតូចលេខ២១ នៃកងយោធពលខេមរភូមិន្ទភូមិភាគទី២ គឺជាកងទ័ពចុងក្រោយបង្អស់ដែលត្រូវដកចេញពីតំបន់ព្រំដែនកម្ពុជា និងថៃ ជិតប្រាសាទព្រះវិហារ និងកំណត់ពេលវេលាចំនួន ៣ដង ទៀតដើម្បីដកកងទ័ពចេញក្នុងរយៈពេលមួយសប្តាហ៍។ ស្របពេលដែលសកម្មភាព និងការកំណត់វិធានការណ៍បណ្តោះអាសន្នរបស់តុលាការយុត្តិធម៌អន្តរជាតិ ជាការគួរឲ្យស្វាគមន៍ដើម្បីបញ្ចប់ជម្លោះដែលបណ្តាលមកពីប្រាសាទព្រះវិហារផ្ទាល់ ក៏ប៉ុន្តែត្រូវមានដំណោះស្រាយដែលដាច់ខាត និងអចិន្ត្រៃយ៍ជាងនេះដើម្បីដោះស្រាយជម្លោះព្រំដែនដែលនៅសល់។ តម្រូវការជាបន្ទាន់មួយទៀតដែលចាំបាច់ គឺត្រូវតែមានការកំណត់ផែនទីព្រំដែនរវាងកម្ពុជា និងថៃឲ្យបានច្បាស់លាស់ ដូចអ្វីដែលមានរវាងកម្ពុជា ឡាវ និងវៀតណាម ដែលនឹងតម្រូវឲ្យមានកិច្ចសហប្រតិបត្តិការមកពីភាគីទាំងសងខាង។ យើងសង្ឃឹមថារាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលដែលទើបនឹងចូលកាន់តំណែងប្រទេសថៃក្នុងពេលថ្មីៗនេះ នឹងធ្វើការជាមួយគ្នាដើម្បីស្វែងរកដំណោះស្រាយបែបសន្តិវិធី និងយូរអង្វែងចំពោះជម្លោះព្រំដែនធានាឲ្យប្រជាពលរដ្ឋធម្មតាអាចរស់នៅក្នុងតំបន់ពោរពេញដោយសន្តិភាព និងសុវត្ថិភាព និងជាការបញ្ចប់ការផ្ទុះអំពើហិង្សារវាងប្រទេសទាំងពីរ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង លោក អ៊ូ វីរៈ តាមរយៈ +៨៥៥ (០)១២ ៤០ ៤០ ៥១ ឬអ៊ីម៉ែល ouvirak@cchrcambodia.org **ឬ លោក រ៉ូបឺត ហ្វីនច៍ +៨៥៥ (០)៧៨ ៨០ ៩៩ ៦០ ឬអ៊ីម៉ែល** robert.finch@cchrcambodia.org